អគ្គិសនីកម្ពុជា
ELECTRICITE DU CAMBODGE

# ២០១៦

# អាហារូបករណ៍អ្នកឯកទេសវ័យក្មេងអគ្គិសនីកម្ពុជា
# EDC Young Professionals Scholarship (EYPS)

ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងអគ្គិសនីកម្ពុជាផ្ទាល់តាមរយៈការផ្ដល់នូវបទពិសោធន៍ និង ចំណេះដឹងពីឯកទេសដែលខ្លួនបានបញ្ចប់ការសិក្សា អគ្គិសនីកម្ពុជាផ្ដល់អាហារូបករណ៍តាមរយៈកម្មវិធី អាហារូបករណ៍អ្នកឯកទេសវ័យក្មេងអគ្គិសនីកម្ពុជា EDC Young Professionals Scholarship (EYPS) ដល់ និយោជិត-កម្មករអគ្គិសនីកម្ពុជាដែលមានសក្ដានុពលទាំងផ្នែកបច្ចេកទេស និងផ្នែកដឹកនាំ បានបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅក្រៅប្រទេស ជាពិសេសបណ្ដាប្រទេសជាសមាជិកអាស៊ាន។



## I- ប្រភេទ ឯកទេស និង ចំនួនអាហារូបករណ៍:

១. ថ្នាក់អនុបណ្ឌិត (Master's Degree) ផ្នែកអគ្គិសនី

អាហារូបករណ៍នេះត្រូវបានផ្ដល់សម្រាប់មុខវិជ្ជាពាក់ព័ន្ធ:

- ✓ Master degree in Electrical Engineering (High Voltage System design and protection) — ចំនួន:០២កន្លែង
- ✓ Master degree in Electrical Engineering (Power System Analysis) — ចំនួន:០១កន្លែង
- ✓ Master degree in Electrical Engineering (Power Plant Design and Modeling) — ចំនួន:០១កន្លែង



## II- លក្ខខណ្ឌនៃការជ្រើសរើស:

- ✓ ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ (ភ្ជាប់ព្រឹត្តិបត្រពិន្ទុ)
- ✓ ត្រូវមានអតីតភាពការងារនៅអគ្គិសនីកម្ពុជា យ៉ាងតិចចំនួន០៣ឆ្នាំ គិតត្រឹមថ្ងៃស្នើសុំអាហារូបករណ៍
- ✓ ត្រូវទទួលបានការអនុញ្ញាត្តិឲ្យសិក្សាជាផ្លូវការ (admission in principles) ពីមហាវិទ្យាល័យ ឬ សាកលវិទ្យាល័យ ដែលសាម៉ីខ្លួនគ្រោងទៅសិក្សាជាមុន
- ✓ ត្រូវមានប្រវត្តិការងារ និងវិន័យល្អចេះធ្វើការជាក្រុម ចេះចែករំលែកបទពិសោធន៍និងចំណេះដឹងជាមួយអ្នកដទៃ មានស្មារតីគោរពវិន័យចាត់តាំងរបស់អង្គភាព ជាអ្នកមានសក្ដានុពលទាំងផ្នែកបច្ចេកទេស និងផ្នែកដឹកនាំ សម្រាប់ទៅថ្ងៃអនាគត



## III- ការផ្ដល់អាទិភាព:

- ✓ ក្នុងករណីចាំបាច់ ចំពោះនិយោជិតអគ្គិសនីកម្ពុជាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌនៃការជ្រើសរើសហើយបានដាក់ពាក្យស្នើសុំអាហារូបករណ៍មុនកាលបរិច្ឆេទកំណត់ និងសមស្របទៅតាមតម្រូវការជំនាញចាំបាច់របស់អគ្គិសនីកម្ពុជា នឹងត្រូវបានផ្ដល់អាទិភាព។



## IV- កាលបរិច្ឆេទ និង ទីកន្លែងទទួលពាក្យ:

- ✓ ផុតកំណត់ថ្ងៃទី៖ ១៥ វិច្ឆិកា ២០១៦
- ✓ ទីកន្លែងទទួលពាក្យ៖ ការិយាល័យមូលនិធិសង្គម និងអាហារូបករណ៍

បញ្ជាក់៖ បេក្ខជនដែលមានចំណាប់អារម្មណ៍ចំពោះអាហារូបករណ៍ខាងលើ អាចមកទទួលពាក្យស្នើសុំនៅ ការិយាល័យមូលនិធិសង្គម និងអាហារូបករណ៍ នៅរៀងរាល់ម៉ោងធ្វើការ ឬ ចូលទៅកាន់ Website: www.edc.com.kh/edcscholarship

ការិយាល័យមូលនិធិសង្គម និងអាហារូបករណ៍ (ម៉ោងធ្វើការ ៧:៣០-១២:០០, ១៤:០០-១៧:៣០, ពី ថ្ងៃច័ន្ទ ដល់ សុក្រ)
អ៊ីម៉ែល៖ edcscholarship@gmail.com ទូរស័ព្ទលេខ៖ ០២៣ ៧២៣ ១៦៣
(អគារ A ជាន់ទី៣) អគ្គិសនីកម្ពុជា #២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ